**ឯកសារសង្ខេប**

គណៈកម្មការទី២នៃព្រឹទ្ធសភាកម្ពុជា

# ការិយាល័យថវិកាសភា (កថស)៖ ទម្រង់ និងដំណើរការ នៅប្រទេសស៊ុយអែត ហ្វាំងឡង់ និងវៀតណាម

ស្រាវជ្រាវដោយ៖ បណ្ឌិត **លុជ្ស លីកាណាន់**

ខែមេសា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើង នាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់ តែជាឯក-សារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែល ពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវសង្ខេបនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

សេចក្តីផ្តើម ...... 1

ប្រទេសដែលជាប្រធានបទនៃការសិក្សា ...... 2

ស៊ុយអែត ...... 2

ហ្វាំងឡង់ ...... 4

វៀតណាម ...... 4

សេចក្តីសន្និដ្ឋាន ...... 6

ឯកសារយោង ...... 7

# សេចក្តីផ្តើម

ទម្រង់ និងមុខងារនៃការិយាល័យថវិកាសភា(**កថស**)[1] មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ នៅប្រទេសស៊ុយអែត **កថស** ត្រូវបានបង្កើតឡើងក្នុងឋានៈជាស្ថាប័នឯករាជ្យមួយតាំងពីឆ្នាំ១៩៩៧ ប៉ុន្តែ វាជាផ្នែកមួយនៃសេវាស្រាវជ្រាវសម្រាប់សភា ដែលត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៥៥ ដើម្បីវិភាគប៉ាន់ប្រមាណថវិកាជាតិ និងពន្ធ។ ប៉ុន្តែ នៅប្រទេសហ្វាំងឡង់ **កថស** ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១១ ក្នុងទម្រង់ជាស្ថាប័នស្រាវជ្រាវសភា ដែលផ្តោតទៅលើការប៉ាន់ប្រមាណថវិកាជាតិ និងការវិភាគសេដ្ឋកិច្ច។ រីឯ នៅប្រទេសវៀតណាមវិញ **កថស** មិនទាន់ត្រូវបានបង្កើតឡើងនៅឡើយទេ ប៉ុន្តែ «គណៈកម្មាធិការសភាដើម្បីកិច្ចការហិរញ្ញវត្ថុ និងថវិកា» បានបំពេញមុខងាររបស់ **កថស** មួយចំនួនដោយអនុលោមទៅតាមច្បាប់ថវិកាជាតិឆ្នាំ២០០២។

បើទោះបីជាទម្រង់ **កថស** មានភាពខុសគ្នាអាស្រ័យលើកាលៈទេសៈ និងវប្បធម៌នយោបាយនៃប្រទេសនីមួយៗក្តី អាណត្តិ និងបេសកកម្មរបស់ **កថស** គឺផ្តល់ដល់បុគ្គលិកសភានូវចំណេះដឹង បច្ចេកទេស និងចំណេះធ្វើ ឬភាសាអង់គ្លេសហៅថា know how (ការបណ្តុះបណ្តាលតាមរយៈការហាត់ការដោយផ្ទាល់)ស្តីពីការវិភាគថវិកា[2]

> “*provide independent and objective analysis to Parliament on the state of the nation’s finances, the government’s estimates and trends in the economy; and upon request from a committee or parliamentarians, to estimate the financial costs of any proposal for matters over which parliament has jurisdiction*”

> «ផ្តល់ជូននូវការវិភាគឯករាជ្យ និងសត្យានុម័តទៅដល់សភាស្តីពីស្ថានភាពហិរញ្ញវត្ថុរបស់ជាតិ ការប៉ាន់ប្រមាណរបស់រដ្ឋាភិបាល និងនិន្នាការសេដ្ឋកិច្ច ព្រមទាំង ធ្វើការប៉ាន់ប្រមាណចំណាយហិរញ្ញវត្ថុនៃគម្រោងសំណើនានា ចំពោះកិច្ចការទាំងឡាយណាដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់សភា ដោយឆ្លើយតបទៅនឹងសំណើរបស់គណៈកម្មាធិការ ឬសមាជិកសភា»។[3]

ឯកសារសង្ខេបនេះនឹងបង្ហាញជូននូវសេចក្តីពណ៌នាសង្ខេបមួយស្តីពីទម្រង់ និងមុខងាររបស់ **កថស** នៅប្រទេសស៊ុយអែត ហ្វាំងឡង់ និងវៀតណាម។

---

[1] "កថសគឺជាអង្គភាពដែលមានជំនាញខ្ពស់ ដែលធ្វើប្រតិបត្តិការដោយសត្យានុម័តដើម្បីលើកថវិកា ហិរញ្ញវត្ថុ និងកម្មវិធីសម្រាប់អ្នកតាក់តែងច្បាប់ ប្រកបដោយឯករាជ្យភាពនិងជំនាញកម្រិតខ្ពស់ និងដោយមិនលម្អៀងបក្សនយោបាយណាឡើយ។"(Cited in PIC. 2014. *Perspectives on Parliamentary Budget office*. Briefing Note, Phnom Penh: Parliamentary Institute of Cambodia, 1-5.)

[2] Fors, Gunnar and Robin Travis. 2015. "Seminar on Parlimentary Budget Offices (PBO)." *Seminar on Parlimentary Budget Offices (PBO).* Phnom Penh: Senate of Cambodia and Parlimantary Institute of Cambodia. 1-28.

[3] Cited in Frechette, Jean-Denis. 2014. *2013-14 Report on Activities of the Parliamentary Budget Office.* Activities Report, Ottawa: Office of the Parliamentary Budget Officer, 1-32.

# ប្រទេសដែលជាប្រធានបទនៃការសិក្សា

## *ស៊ុយអែត*

ទម្រង់នៃ **កថស** នៅប្រទេសស៊ុយអែត គ្របដណ្តប់លើការងារនៃ **កថស** ទាំងមូល ហើយចែកជាស្ថាប័នសំខាន់ៗបី៖ **កថស** ក្រុមប្រឹក្សាគោលនយោបាយហិរញ្ញវត្ថុ និងលេខាធិការដ្ឋាននៅក្នុងគណៈកម្មាធិការសភានានា។ **កថស** ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ ជាផ្នែកមួយនៃសេវាស្រាវជ្រាវសភា(ជាពិសេសនៅក្នុងផ្នែកវិភាគសេដ្ឋកិច្ច) ស្របទៅតាមកិច្ចផ្តួចផ្តើមរបស់សមាជិកសភា ដោយទទួលបានហិរញ្ញប្បទានពីសភាប្រទេសស៊ុយអែត ពីព្រោះថាសភាចាំបាច់ត្រូវការឲ្យមានសមត្ថកិច្ចក្នុងស្ថាប័នខ្លួនដែលមានជំនាញ និងសមត្ថកិច្ចសម្រាប់ប៉ាន់ស្មាននូវផលប៉ះពាល់ទៅលើថវិការដ្ឋនៃសំណើ ឬគម្រោងសេដ្ឋកិច្ចនានា។ នៅពេលមិនទាន់មាន **កថស** សមាជិកសភាក៏ដូចជាសមាជិកគណបក្សប្រឆាំងនានា ត្រូវធ្វើទំនាក់ទំនងទៅក្រសួងពាក់ពន្ធ័នានាដើម្បីប៉ាន់ប្រមាណនូវផលប៉ះពាល់ទៅលើសំណើសេដ្ឋកិច្ច។ គោលបំណងនៃ **កថស** គឺធ្វើឲ្យធនធានរបស់សភាមានតុល្យភាពជាមួយនឹងធនធានរបស់ក្រសួងនានារបស់រដ្ឋាភិបាល។ **កថស** នៅប្រទេសស៊ុយអែត បានចាប់ផ្តើមដំណើរការដោយមានបុគ្គលិកត្រឹមតែពីរនាក់ប៉ុណ្ណោះ ហើយបន្តិចម្តងៗ បានបង្កើនចំនួនបុគ្គលិកបាន ៦ នាក់ និងអ្នកគ្រប់គ្រងម្នាក់ដែលផ្តល់នូវកិច្ចតម្រង់ទិស និងសេចក្តីណែនាំបច្ចេកទេស និងគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់ការិយាល័យនោះ។

បើទោះបីជា បុគ្គលិករបស់ **កថស** មានចំនួនតិចជាង **កថស** ដ៏ទៃទៀតក្តី ក៏ **កថស** របស់ប្រទេសស៊ុយអែត បានធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ដោយសារបុគ្គលិកទាំង ៦រូបនោះ គឺសុទ្ធតែជាសេដ្ឋវិទូ (អ្នកជំនាញសេដ្ឋកិច្ច) ដែលទទួលបានការបណ្តុះបណ្តាលខ្ពស់។ ដោយមានសំណូមពរពីសភា **កថស** របស់ប្រទេសស៊ុយអែតបានផលិតរបាយការណ៍ប្រមាណជា ៦០០ ជារៀងរាល់ឆ្នាំ ដែលរបាយការណ៍នីមួយៗមានកំរាស់ពី២ទៅ១០ទំព័រ ។

ដោយសារតែ **កថស** ត្រូវបានបង្កើតឡើងដើម្បីបម្រើសមាជិក និងគណៈកម្មការសភា **កថស** ធ្វើកិច្ចការតែទៅតាមសំណើរបស់សមាជិក និងគណៈកម្មការសភាប៉ុណ្ណោះ គឺមិនមានកិច្ចផ្តួចផ្តើមផ្ទាល់ខ្លួនឡើយ ហើយ **កថស** ធ្វើការបម្រើតែលេខាធិការដ្ឋានគណបក្ស សមាជិកសភា និងគណៈកម្មការនានាប៉ុណ្ណោះ។ ទោះយ៉ាងណាក៏ដោយ អ្វីដែលគួរឲ្យកត់សម្គាល់ផងដែរនោះគឺថា បន្ទាប់ពី **កថស** ត្រូវបានបង្កើតមក មិនត្រឹមតែអតិថិជនដូចដែលបានរៀបរាប់ពីខាងលើនេះទេ ដែលប្រើប្រាស់សេវារបស់ **កថស** ប៉ុន្តែគ្រប់គណបក្សទាំងអស់សុទ្ធតែប្រើប្រាស់សេវានេះ ដោយរាប់ទាំងគណបក្សប្រឆាំងផងដែរ។

**កថស** របស់ប្រទេសស៊ុយអែតគឺឯករាជ្យ មិនប្រកាន់បក្សនយោបាយ និងសត្យានុម័ត។ ដោយផ្អែកលើគោល-ការណ៍ទាំងនេះ **កថស** ផ្តល់ជូនអតិថិជននូវការប៉ាន់ប្រមាណអំពីផលប៉ះពាល់ហិរញ្ញវត្ថុ ដែលទាក់ទងទៅនឹងសំណើគោលនយោបាយនានា។ ព័ត៌មានទាំងនេះតែងតែត្រូវបានប្រើប្រាស់នៅក្នុងកិច្ចពិភាក្សាជាលក្ខណៈគោលនយោបាយ ពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុសាធារណៈ និងការធ្វើថវិកា និងដើម្បីរៀបចំគោលនយោបាយសេដ្ឋកិច្ចដទៃទៀត។

ការជជែកជេញដោលប្រកបដោយអត្ថន័យខ្ពស់ស្តីពីថវិកា តម្រូវឲ្យមានរបាយការណ៍ **កថស** ដែលមានលក្ខណៈត្រឹមត្រូវ ដោយប្រើប្រាស់ព័ត៌មានថ្មីបំផុតពី**ស្ថាប័នស្ថិតិរបស់រដ្ឋស៊ុយអែត។** ឧទាហរណ៍ ដើម្បីស្វែងយល់ពីផលប៉ះពាល់នៃសំណើពន្ធរបស់រដ្ឋាភិបាលលើចរន្តចំណូល ឬទៅលើស្ថានភាពសុខមាលភាពនៃក្រុមប្រជាជនផ្សេងៗ បុគ្គលិក **កថស** ចាំបាច់ត្រូវប្រើប្រាស់ម៉ូដែល (Model) សេដ្ឋកិច្ចល្អិតល្អន់ ដែលពេលខ្លះស្រដៀងគ្នាទៅនឹងម៉ូដែលដែលត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ដែលអាចផ្តល់នូវការប៉ាន់ប្រមាណសមហេតុផល ដើម្បីផ្តល់ជាព័ត៌មានដល់សមាជិកសភា។[4]

កិច្ចការសំខាន់មួយទៀតរបស់ **កថស** គឺ «ការប៉ាន់ប្រមាណចំណាយរបស់គោលនយោបាយនីមួយៗ» ដែលនឹងត្រូវអនុវត្តដោយរដ្ឋាភិបាល។ នេះគឺជាការចាំបាច់ ដើម្បីធ្វើឲ្យអតិថិជនយល់ដឹងអំពីភាពប្រទាក់ក្រឡានៃផលប៉ះពាល់ទៅលើថវិការដ្ឋ នៃសំណើ ឬគម្រោងសេដ្ឋកិច្ចនីមួយៗ។ បន្ទាប់ពីសំណើ ឬគម្រោងថវិកាត្រូវបានអនុម័ត និងត្រូវបានអនុវត្តរួចហើយ មានការតម្រូវឲ្យតាមដាន និងវាយតម្លៃទៅលើការអនុវត្តនោះ ដែលគេហៅដំណាក់កាលនេះថាជាការវាយតម្លៃ«ក្រោយព្រឹត្តិការណ៍ (ex-post)» ឬការវាយតម្លៃដែលផ្អែកលើទិន្នន័យនៃការអនុវត្តនោះនៅពេលដែលគម្រោងសំណើថវិកានោះបានអនុវត្តគ្រប់ជ្រុងជ្រោយ។ គួរឲ្យកត់សម្គាល់ផងដែរថា **កថស** របស់ប្រទេសស៊ុយអែត មិនផ្តល់ជូននូវការព្យាករណ៍ និងអនុសាសន៍ស្តីពីគោលនយោបាយសារពើពន្ធទេ។

ការកសាងសមត្ថភាពរបស់បុគ្គលិកមន្ត្រីសភានៅគណៈកម្មការ និងមន្ត្រីលេខាធិការដ្ឋាន តាមរយៈការបណ្តុះបណ្តាលដោយធ្វើការងារផ្ទាល់ និងការផ្ទេរចំណេះដឹង គឺជាគោលបំណងសំខាន់មួយទៀតរបស់ **កថស**។ តាមរយៈវិធីសាស្ត្រនេះ លេខាធិការដ្ឋាន និងបុគ្គលិកសភាដែលមានគុណសម្បត្តិគ្រប់គ្រាន់ អាចរៀនសូត្រអំពីវិធីវិភាគថវិកា និងយល់ដឹងអំពីការវិភាគសេដ្ឋកិច្ចដែលធ្វើឡើងដោយអ្នកជំនាញ។ ជាលទ្ធផលបុគ្គលិកទាំងនេះអាចប្រើប្រាស់ជំនាញដែលបានរៀនកាន់តែច្រើនស្តីពីបញ្ហាថវិកាដើម្បីបម្រើសមាជិកសភា។

ក្រុមប្រឹក្សាគោលនយោបាយសារពើពន្ធរបស់ស៊ុយអែត (Fiscal Policy Council) គឺជាស្ថាប័នមួយផងដែរ ដែលត្រូវបានបង្កើតឡើង ដោយឯករាជ្យពីសភា ដោយទទួលបានថវិកាពីរដ្ឋាភិបាល។ ខុសពី **កថស** ស្ថាប័ននេះអាចធ្វើកិច្ចការដោយផ្អែកលើគំនិតផ្តួចផ្តើមខ្លួនឯងផ្ទាល់។ តួនាទីរបស់ក្រុមប្រឹក្សានេះគឺដូចនឹងតួនាទីរបស់ **កថស** ប៉ុន្តែចំណុចផ្តោតសំខាន់របស់ស្ថាប័ននេះគឺប៉ាន់ប្រមាណថាតើគោលនយោបាយសារពើពន្ធ និងសេដ្ឋកិច្ចរបស់រដ្ឋាភិបាលសម្រេចគោលដៅរបស់ខ្លួនបានឬទេ មាននិរន្តភាពឬទេ និងមានតម្លាភាពដែរឬទេ។

ស្ថាប័នសំខាន់មួយទៀតដែរនោះគឺលេខាធិការដ្ឋាននៅក្នុងគណៈកម្មាធិការនានា ដែលផ្តោតតែទៅលើ «ការវាយតម្លៃ» គោលនយោបាយសារពើពន្ធ និងសេដ្ឋកិច្ចតែប៉ុណ្ណោះ។

---

[4] SR. 2011. *Utredningstjansten.* Briefing note, Stockhom: Seriges Riksdag.

## *ហ្វាំងឡង់*

គួឲ្យកត់សម្គាល់ផងដែរថា **កថស** របស់ប្រទេសហ្វាំងឡង់គឺស្រដៀងទៅនឹង **កថស** របស់ប្រទេសស៊ុយអែត។ **កថស** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ដើម្បីធ្វើការប៉ាន់ស្មានសំណើថវិកា និងការវិភាគសេដ្ឋកិច្ច។ មុខងារនៃ **កថស** គឺបំពេញដោយស្ថាប័នពីរៈ ការិយាល័យសវនកម្មជាតិ (ដែលត្រួតពិនិត្យការប្រតិបត្តិតាមវិធានគោលនយោបាយសារពើពន្ធ) និង **កថស** ដែលស្ថិតនៅក្នុងនាយកដ្ឋានស្រាវជ្រាវសភា (ដែលធ្វើការតាមសំណើពីសមាជិកសភា និងប៉ាន់ស្មានចំណាយនានាតាមសំណើ)។ សមត្ថភាពវិភាគសេដ្ឋកិច្ចរបស់ **កថស** ត្រូវបានពង្រឹងក្នុងអណត្តិ២០១១-២០១៥ របស់សភា។ ក្រុមអ្នកវិភាគសេដ្ឋកិច្ច មានសេដ្ឋវិទូចំនួន ៤រូប និងទីប្រឹក្សាច្បាប់ចំនួនមួយរូប។

**កថស** ដែលមានតួនាទីត្រូវបម្រើសមាជិកសភា ក្រុមនៅក្នុងសភា និងគណៈកម្មការនានា (ទាំងគណបក្សប្រឆាំង និងរដ្ឋាភិបាល ប្រើប្រាស់សេវារបស់ **កថស**) រួមមានសេវា/ផលិតផលសំខាន់ៗចំនួនបី ពោលគឺៈ

- ការវាយតម្លៃ (ម៉ាក្រូ និងមីក្រូ) នៃផលប៉ះពាល់នៃការផ្លាស់ប្តូរគោលនយោបាយសេដ្ឋកិច្ចដូចដែលបានលើកស្នើឡើង (ពោលគឺ ការប៉ាន់ប្រមាណចំណាយ)។ ភាគច្រើននៃការវិភាគនេះផ្តោតទៅលើផលប៉ះពាល់នៃកំណែទម្រង់ទៅលើប្រព័ន្ធអត្ថប្រយោជន៍ពន្ធ។ លទ្ធផលនៃការវិភាគនេះត្រូវបានគេប្រើប្រាស់ជារឿយៗ ដើម្បីធ្វើការប្រៀបធៀបជាមួយនឹងសំណើនានារបស់រដ្ឋាភិបាល ព្រមទាំងអាចយកទៅប្រើប្រាស់ដើម្បីបង្កើតជម្រើសសំណើគោលនយោបាយថវិកាផ្សេងពីនេះបាន (Alternative Policies)។
- ការពិនិត្យផ្នែកសេដ្ឋកិច្ច និងការធ្វើសង្ខេបទៅលើរាល់ជំនាញរបស់វិទ្យាសាស្ត្រសេដ្ឋកិច្ច និងប្រធានបទជាក់លាក់ទាំងឡាយ ដែលជាទូទៅជាប់ពាក់ព័ន្ធទៅនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន (ឧទាហរណ៍ៈ ថាមពល សុវត្ថិភាពសង្គម ។ល។) និង
- ស្ថិតិ និងការទាញយកព័ត៌មាន ដែលអាចយកទៅប្រើប្រាស់សម្រាប់ជម្រើសសំណើគោលនយោបាយថវិកា និងរបាយការណ៍គោលនយោបាយ។ល។

បន្ថែមពីលើសេវាទាំងនេះ មុនពេលការបោះឆ្នោតសភានៅឆ្នាំ២០១៥ ប្រធានសភាបានជម្រាបគណបក្សនៅក្នុងសភាទាំងអស់ថា ពួកគេអាចប្រើប្រាស់សេវា **កថស** ដើម្បីប៉ាន់ប្រមាណចំណាយ ទៅលើការឃោសនាបោះឆ្នោតរបស់គណបក្សនានា (election manifestos)។ គ្រប់គណបក្សបានទទួលប្រយោជន៍ពីសេវានេះ ហើយកម្មវិធីដែលបានឃោសនាក្នុងពេលបោះឆ្នោតចំនួនជាង១០០ ដែលបង្ហាញពីកម្មវិធីកំណែទម្រង់ ត្រូវបានគេធ្វើការប៉ាន់ប្រមាណ។

## *វៀតណាម*

ប្រទេសវៀតណាមបានកសាង (មន្ត្រីដែលមាន) សមត្ថភាពនៅក្នុងសភា ដើម្បីធ្វើកិច្ចការដែលជារបស់ **កថស** តាមរយៈគណៈកម្មាធិការកិច្ចការហិរញ្ញវត្ថុ និងថវិកា (គកហថ-Financial and Budget Affairs (CFBA))។ សេចក្តីសម្រេចលេខ៣៨៧ របស់សភាជាតិ កំណត់អំពីការចូលរួមយ៉ាងសកម្មនៃ **គកហថ** នៅក្នុងការតាមដានពិនិត្យថវិកា ហើយបន្ទាប់មក **គកហថ** ធ្វើសេចក្តីរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញ

អង្គរបស់សភាស្តីពីបញ្ហាថវិកា។ គណៈកម្មាធិការដទៃទៀតរបស់សភាជាតិត្រូវផ្តល់របាយការណ៍ទៅ **គកហថ** ស្តីពីបញ្ហាពាក់ពន្ធ័នឹងថវិកាជាតិ ។ សភាពុំអនុម័តទៅលើក្របខណ្ឌថវិកាទាំងមូល និងទៅលើការប៉ាន់ប្រមាណនៃការចំណាយឡើយ។ កិច្ចការទាំងអស់ទាក់ទងទៅនឹងការវិភាគថវិកាត្រូវធ្វើឡើងនៅក្នុងសិក្ខាសាលារបស់រដ្ឋាភិបាល ឬ **គកហថ** មុននឹងសម្រេចទៅលើថវិកាទាំងមូលជា«កញ្ចប់»។ ពាក់ព័ន្ធទៅនឹងបញ្ហាបុគ្គលិក **គកហថ** មានបុគ្គលិកមានគុណសម្បត្តិគ្រប់គ្រាន់ (៣៧នាក់) ដែលភាគច្រើននៃអ្នកទាំងនេះគឺជាអតីតបុគ្គលិករបស់ក្រសួងហិរញ្ញវត្ថុ ដែលអាចវិភាគសេចក្តីព្រាងថវិកាបាន។

រដ្ឋមន្ត្រីនានា ពុំមានទំនួលខុសត្រូវជាលក្ខណៈបុគ្គលនៅចំពោះមុខសភាជាតិទេ នៅពេលវិភាគពីថវិកាប្រចាំឆ្នាំ ប៉ុន្តែ ដំណើរការរួមគ្នាមួយ (collective process) ត្រូវបានយកមកប្រើ ដែលក្នុងនោះការប្រជុំការងាររៀបចំដោយ **គកហថ** មានការចូលរួមពីទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ។ ដំណើរការនេះអាចធ្វើតាមវិធីមួយទៀត ដែលក្នុងនោះ ក្រសួងហិរញ្ញវត្ថុធ្វើគណនីថវិកាជាតិចុងក្រោយបំផុតទៅរដ្ឋាភិបាល និង **គកហថ** ក្នុងពេលតែមួយ ហើយដែល **គកហថ** ត្រូវបានអញ្ជើញឲ្យចូលរួមអង្គប្រជុំការងារជាមួយរដ្ឋាភិបាល។ តាមរយៈដំណើរការនេះ ទាំងរដ្ឋាភិបាល និង **គកហថ** មានគណនេយ្យភាពចំពោះមុខគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភាជាតិ ដោយសាររដ្ឋាភិបាល និង **គកហថ** ត្រូវបានណែនាំឲ្យធ្វើសហប្រតិបត្តិការ និងបំពេញរបាយការណ៍ស្តីពីការអនុវត្តថវិកាជាតិចុងក្រោយបំផុតសម្រាប់បញ្ជូនទៅសភាជាតិ។[5]

ច្បាប់ថវិកាជាតិឆ្នាំ២០០២ ចែងអំពីមូលដ្ឋានគតិយុត្តសម្រាប់ការធ្វើថវិកានៅគ្រប់កម្រិតនៃរដ្ឋាភិបាល រួមទាំងបុរេត្រួតពិនិត្យថវិកា (pre-examining) ដោយរដ្ឋសភាជាតិ មុនថ្ងៃ១ ខែឧសភា រៀងរាល់ឆ្នាំ។[6]

នៅប្រទេសវៀតណាម ជាគោលការណ៍ ថវិការដ្ឋាភិបាលត្រូវបានចំណាត់ថ្នាក់ជា៖១) អង្គភាពរដ្ឋបាល ដែលផ្តល់ព័ត៌មានអំពីជំពូកសំខាន់ៗ (ដូចជា៖ក្រសួងផ្សេងៗ) នៅកម្រិតរដ្ឋាភិបាលកណ្តាល និងកម្រិតខេត្តផងដែរ។ ២)តាមមុខងារ ដែលសំដៅទៅលើខ្ទង់ចំណាយនានា ដែលរដ្ឋាភិបាលផ្តល់ថវិកាឲ្យ។ និង ៣) ផ្នែកសេដ្ឋកិច្ច ដែលឯកសារផ្សព្វផ្សាយជាសាធារណៈបង្ហាញតែពីចំណាយចរន្ត(recurrent spending) (បំបែកជា១១មុខងារតូចៗ) និងចំណាយមូលធនដុល (មិនបែងចែកតាមមុខងារ លើកលែងតែវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា)។

នៅក្នុងការអនុវត្តជាក់ស្តែង ថវិកាប្រចាំឆ្នាំដែលបានបង្ហាញទៅសភាជាតិ និងក្រុមប្រឹក្សាខេត្ត មានលក្ខណៈទូលំទូលាយ ហើយភាគច្រើនថវិកានេះបានចែកជាប្រភេទស្ថាប័នរដ្ឋបាល និងប្រភេទមុខងារ សម្រាប់ចំណាយចរន្ត ប៉ុន្តែមិនមែនចំណាយមូលធន។[7] ជារឿងគួរឲ្យចាប់អារម្មណ៍នោះគឺថា ដោយសារតែប្រទេសវៀតណាមពុំទាន់ទទួលយកប្រព័ន្ធអនុវត្តថវិកាតម្រង់ទិសនៅឡើយ (performance-oriented budget system) ហើយសូចនាករការអនុវត្ត (performance indicators) មិនមែនជាផ្នែកនៃសំណើថវិការបស់ក្រសួង/ទីភ្នាក់ងារ/ខេត្ត

---

[5] Ibid.
[6] Ibid.
[7] Lienert, Ian. 2014. *Parliamentary Budget and Transparency in Six ASEAN Countries.* Working Paper Based on Outcome

ឡើយ (ឬអាចនិយាយបានថា ក្រសួង/ទីភ្នាក់ងារ/ខេត្តនានា មិនទាន់ដាក់បញ្ចូលសូចនាករការអនុវត្តទៅក្នុងសំណើថវិការបស់ខ្លួននៅឡើយ)។

## សេចក្តីសន្និដ្ឋាន

**កថស** នៅប្រទេសស៊ុយអែត និងប្រទេសហ្វាំងឡង់ និង **កគថស** នៅប្រទេសវៀតណាម ត្រូវបានបង្កើតឡើងដើម្បីផ្តល់ឲ្យសមាជិកសភា គណៈកម្មាធិការ និងលេខាធិការដ្ឋាននូវការវិភាគថវិកា ការប៉ាន់ប្រមាណការចំណាយថវិកា និងការវិភាគសេដ្ឋកិច្ចនៅកម្រិតម៉ាក្រូ និងមីក្រូ ដើម្បីឲ្យពួកគេយល់កាន់តែច្បាស់អំពីថវិកា និងដំណើរការធ្វើថវិកា។

**កថស** នៅប្រទេសស៊ុយអែត មានភាពចាស់ទុំ និងរឹងមាំជាង **កថស** នៅប្រទេសដទៃទៀត ហើយបានបំពេញគ្រប់មុខងារទៅតាមសំណើទាំងអស់ដែលទាក់ទងទៅនឹងការវិភាគសេដ្ឋកិច្ច និងការធ្វើថវិកាពីសំណាក់សមាជិកសភា គណៈកម្មាធិការ និងគណបក្សនយោបាយនៅក្នុងសភា។ ដែលសំខាន់ជាងនេះ **កថស** ផ្តល់ជូនផងដែរនូវការបណ្តុះបណ្តាលបច្ចេកទេស ដល់មន្ត្រីគណៈកម្មាធិការ និងមន្ត្រីលេខាធិការដ្ឋានដែលមានគុណសម្បត្តិគ្រប់គ្រាន់ តាមរយៈការធ្វើការដោយផ្ទាល់ និងការផ្តល់ព័ត៌មានអំពីថវិកា ដើម្បីពង្រឹងការជជែកវែកញែកនយោបាយ និងទិន្នន័យមិនលម្អៀងដែលអាចយកទៅប្រើប្រាស់ដើម្បីបង្កើតជម្រើសសំណើថវិកាផ្សេងទៀត។

**កថស** នៅប្រទេសហ្វាំងឡង់ មានសភាពដូចគ្នាទៅនឹង **កថស** នៅប្រទេសស៊ុយអែតដែរ ដោយផ្តល់នូវការប៉ាន់ប្រមាណចំណាយសំណើថវិកា និងការវិភាគសេដ្ឋកិច្ច។ ក្រុមការងារសេដ្ឋកិច្ចក៏ធ្វើការវិភាគផងដែរនូវផលប៉ះពាល់នៃបញ្ហាសេដ្ឋកិច្ចណាមួយ (ដូចជា៖ ភាពមានការងារធ្វើ) និងសិក្សាស្រាវជ្រាវផងដែរលើផ្នែកសេដ្ឋកិច្ចទៅតាមសំណើ។ លើសពីនេះ **កថស** របស់ប្រទេសហ្វាំងឡង់ក៏ផ្តល់ផងដែរនូវការប៉ាន់ប្រមាណចំណាយលើការឃោសនាបោះឆ្នោតរបស់គណបក្សនានា (costing of manifestos) ទៅគ្រប់គណបក្សនយោបាយទាំងអស់នៅក្នុងសភាមុនពេលបោះឆ្នោត។

**កថស** នៅប្រទេសវៀតណាមមិនទាន់ត្រូវបានបង្កើតនៅឡើយទេ ប៉ុន្តែ **គកហថ** បានបំពេញកិច្ចការខ្លះ ដែលជាមុខងាររបស់ **កថស** ដូចជាត្រួតពិនិត្យផ្នែកនានានៃថវិកា ហើយរាយការណ៍ទៅកាន់សភាជាតិ និង/ឬគណៈកម្មា-ធិការអចិន្ត្រៃយ៍អំពីរបកគំហើញរបស់ខ្លួន។

## ឯកសារយោង


Fors, Gunnar and Robin Travis. 2015. "Seminar on Parlimentary Budget Offices (PBO)." *Seminar on Parlimentary Budget Offices (PBO)*. Phnom Penh: Senate of Cambodia and Parlimantary Institute of Cambodia. 1-28.

Frechette, Jean-Denis. 2014. *2013-14 Report on Activities of the Parliamentary Budget Office*. Activities Report, Ottawa: Office of the Parliamentary Budget Officer, 1-32.

Lienert, Ian. 2014. *Parliamentary Budget and Transparency in Six ASEAN Countries*. Working Paper Based on Outcome of AIPA Capacity Building Workshop, AIP, German Cooperation, and GIZ.

SR. 2011. *Utredningstjansten.* Briefing note, Stockhom: Seriges Riksdag.